អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អៀង សារី ហៅ វ៉ាន់



| | |
|---|---|
| **គោត្តនាម:** អៀង | **នាម:** សារី |

**សំណុំរឿងលេខ** ៖ ០០២/១៩-០៩-២០០៧/អវតក-អជសដ

**សវនាការសាធារណៈលើកក្រោយ** ៖ ២៧ មិថុនា ២០១១

**កាលបរិច្ឆេទនិងទីកន្លែងកំណើត** ៖ ថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩២៥ នៅភូមិលឿងវ៉ា ខេត្តត្រាវីញ (វៀតណាមខាងត្បូង)

**ចាប់ខ្លួន** ៖ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧

**មេធាវីការពារក្តី៖** លោកក អាង ឧត្តម (មេធាវីជាតិ) និងលោក ម៉ៃឃើល ខាណាវ៉ាស (Micheal G. Karnavas) (មេធាវីអន្តរជាតិ ជនជាតិអាមេរិក)

| | |
|---|---|
| **ស្ថានភាពបច្ចុប្បន្ន** | ត្រូវចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះពីបទ **ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា** ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងមានចែងនិងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី) មាត្រា៤, ៥, ៦, ២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។<br>សវនាការបឋមនឹងចាប់ផ្តើមនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។ |
| **តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ** | ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍និងគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា |

| | |
|---|---|
| **បទចោទប្រកាន់សំខាន់ៗ** | អៀង សារី ត្រូវបានចោទប្រកាន់ថា មានការទទួលខុសត្រូវតាមរយៈការធ្វើសកម្មភាព ឬ បរាជ័យក្នុងការទប់ស្កាត់(រួមបញ្ចូលទាំងការប្រព្រឹត្តតាមរយៈឧក្រិដ្ឋកម្ម រួម) បញ្ជា ញុះញង់ រៀបចំផែនការ ដឹកនាំ ឬសមគំនិត ដោយការជួយឬជំរុញ ឬបង្កលក្ខណៈងាយស្រួលដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំ ចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម ដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩៖<br><br>**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។<br><br>**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍** ៖ ការសម្លាប់ក្រុមជនជាតិវៀតណាម និង ចាម។<br><br>**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩** ៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរឬឲ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំងនិងការនិរទេសជនស៊ីវិលដោយខុសច្បាប់។<br><br>**អំពើមនុស្សឃាត** ៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនាដូចមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។<br>អៀង សារី បានបដិសេធរាល់បទចោទប្រកាន់ទាំងអស់មកលើគាត់។ |
| **ប្រវត្តិរូបផ្ទាល់ខ្លួន** | អៀង សារី គឺជាអតីតសិស្សនៅវិទ្យាល័យស៊ីសុវត្ថិ ក្នុងក្រុងភ្នំពេញ។ លោកបានទទួលអាហារូបករណ៍ទៅសិក្សានៅឯវិទ្យាល័យកុងដ័រសេ និងនៅវិទ្យាស្ថានសិក្សានយោបាយក្រុងប៉ារីសប្រទេសបារាំង។ លោកបានចូលជាសមាជិកបក្សកុម្មុយនីស្តបារាំងក្នុងឆ្នាំ១៩៥១។ អៀង សារី ត្រូវបានគេជឿថាបានចូលរួមជាមួយ ខៀវ សំផន ក្នុងការបង្កើតចលនា ម៉ាក្សស៊ីស ក្នុងស្រទាប់និស្សិតកម្ពុជានៅប្រទេសបារាំង។ បន្ទាប់ពីត្រឡប់មកកម្ពុជាវិញក្នុងឆ្នាំ១៩៥៧ អៀង សារី បានក្លាយជាគ្រូបង្រៀនប្រវត្តិវិទ្យានៅវិទ្យាល័យស៊ីសុវត្ថិ និងជាសមាជិកសកម្មនៃបក្សកុម្មុយនីស្តកម្ពុជា។ |

អៀង សារី បានរត់ចូលព្រៃដើម្បីចូលរួមជាមួយចលនាខ្មែរក្រហមនៅឆ្នាំ១៩៦៣។ ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧១-១៩៧៥ លោកបានចូលរួមជាមួយរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងជាបេសកជនពិសេសរបស់រណសិរ្សរួបរួមជាតិខ្មែរ។

ពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅឆ្នាំ១៩៧៥ អៀង សារី ក៏បានក្លាយទៅជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស។ អៀង សារី បានរត់ភៀសខ្លួនទៅប្រទេសថៃនៅពេលដែលរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩។ គាត់ត្រូវបានកាត់ទោសកំបាំងមុខពីបទប្រល័យពូជសាសន៍ និងត្រូវផ្តន្ទាទោសប្រហារជីវិតដោយតុលាការប្រជាជនបដិវត្តន៍កម្ពុជានៅភ្នំពេញ។ អៀង សារី បានបន្តតួនាទីរបស់ខ្លួនក្នុងរដ្ឋាភិបាលនិរទេស ប៉ុន្តែបានផ្ទេរមុខតំណែងជារដ្ឋមន្ត្រីការបរទេសទៅឲ្យ ខៀវ សំផន បន្ទាប់ពីការបង្កើតរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៨២។ អៀង សារី បានចាកចេញពីចលនាខ្មែរក្រហមជាមួយនឹងកងកម្លាំងយោធារាប់ពាន់នាក់នៅខែសីហាឆ្នាំ១៩៩៦ ជាថ្នូរនឹងព្រះរាជក្រិត្យលើកលែងទោសចំពោះសាលក្រមឆ្នាំ១៩៧៩ និងការលើកលែងទោសពីសំណាក់ព្រះករុណាព្រះបាទ នរោត្តម សីហនុ ពីការកាត់ទោសក្រោមច្បាប់ដាក់ខ្មែរក្រហមនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤។

| | | |
|---|---|---|
| **ប្រវត្តិនៃសំណុំរឿង** | ១២ វិច្ឆិកា ២០០៧ | អៀង សារី ត្រូវចាប់និងឃុំខ្លួនក្រោមអំណាចរបស់នគរបាលយុត្តិធម៌ |
| | ១៤ វិច្ឆិកា ២០០៧ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចឃុំខ្លួន អៀង សារី ជាបណ្តោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំ |
| | ១៥ មករា ២០០៨ | អៀង សារី ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១៧ តុលា ២០០៨ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១០ វិច្ឆិកា ២០០៨ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចពន្យារពេលឃុំ ខ្លួន អៀង សារី ជាបណ្តោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំទៀត |

| | | |
|---|---|---|
| | ១០ ធ្នូ ២០០៨ | អៀង សារី  ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ២៦ មិថុនា ២០០៩ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១០ វិច្ឆិកា ២០០៩ | សហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចពន្យារពេលឃុំខ្លួន អៀង សារី ជាបណ្តោះអាសន្នសម្រាប់រយៈពេលមួយឆ្នាំទៀត |
| | ៧ ធ្នូ ២០០៩ | អៀង សារី ដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១៤ មករា ២០១០ | សហចៅក្រមស៊ើបអង្កេតចេញសេចក្តីជូនដំណឹងទៅ អៀង សារី អំពីការពិចារណារបស់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការស៊ើបអង្កេត |
| | ៣០ មេសា ២០១០ | អង្គបុរេជំនុំជម្រះបដិសេធបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាពន្យារពេលឃុំខ្លួនគាត់ជាបណ្តោះអាសន្ន |
| | ១៩ កក្កដា ២០១០ | សហចៅក្រមស៊ើបអង្កេតបញ្ជូនឯកសារសំណុំរឿងទៅសហព្រះរាជអាជ្ញា ដើម្បីឲ្យសហព្រះរាជអាជ្ញារៀបចំសេចក្តីសន្និដ្ឋានស្ថាពរ |
| | ១៦ សីហា ២០១០ | សហព្រះរាជអាជ្ញាចេញសេចក្តីសន្និដ្ឋានស្ថាពរ និងលើកសំណើទៅសហចៅក្រមស៊ើបអង្កេតឲ្យចោទប្រកាន់ អៀង សារី និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| | ១៥ កញ្ញា ២០១០ | សហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ដោយចោទប្រកាន់ អៀង សារី និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ អៀង សារី ត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងជាបណ្តោះអាសន្នរហូតដល់ពេលដែលត្រូវនាំយកទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ |

## ព័ត៌មានទាក់ទងនឹងសំណុំរឿង

| | | |
|---|---|---|
| | ២២ តុលា ២០១០ | អៀង សារី ដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ជំទាស់ទៅនឹងយុត្តាធិការនៃដីកាដំណោះស្រាយ |
| | ១៣ មករា ២០១១ | អង្គបុរេជំនុំជម្រះបានបញ្ចាក់និងធ្វើវិសោធនកម្មដោយផ្នែកទៅលើបទចោទប្រកាន់ប្រឆាំងនឹង អៀង សារី ដែលមានចែងនៅក្នុងដីកាដំណោះស្រាយ និងសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ អៀង សារី ត្រូវបានបន្តឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងជាបណ្ដោះអាសន្នរហូតដល់ពេលដែលត្រូវនាំយកទៅជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ |

*ដីកានិងសេចក្ដីសម្រេចទាំងនេះ និងផ្សេងៗទៀត សូមមើល:

http://www.eccc.gov.kh/document/court

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានទាក់ទងនឹងសំណុំរឿងនេះរៀបចំដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ដើម្បីជាជំនួយដល់សាធារណជន ឲ្យមានការយល់ដឹងអំពីសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក។ ឯកសារនេះពុំមែនជាឯកសារផ្លូវការផ្នែកច្បាប់ណាមួយនោះទេ បើទោះបីជាមានការខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដើម្បីធានាដល់តម្លាភាពព័ត៌មានក៏ដោយ។

**អាសយដ្ឋាន:** ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ ប្រអប់សំបុត្រលេខ៧១ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥)២៣ ២១៩ ៨១៤
ទូរសារ: (៨៥៥) ២៣ ២១៩ ៨៤១
សារអេឡិកត្រូនិក: info@eccc.gov.kh

http://www.eccc.gov.kh